# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៦៤ អយក.សជណ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតមូលដ្ឋានឯកទេសអប់រំកាយ និងកីឡា ជំនាន់ទី៣១ នៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា សម្រាប់ឆ្នាំ២០២៣

យោង៖ - លិខិតលេខ២២៥អយក.បល ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ របស់ក្រសួងអប់រំ យុវជន និងកីឡា
- បញ្ជីប៉ុស្តិ៍អនុវិទ្យាល័យ/វិទ្យាល័យសម្រាប់ការប្រឡងជ្រើសគរុសិស្ស គរុនិស្សិតកម្រិតមូលដ្ឋាន ឆ្នាំ២០២៣ របស់ខេត្តនានា ។

## ក្រសួងអប់រំ យុវជន និងកីឡា

សូមជូនដំណឹងដល់សិស្ស និស្សិតឱ្យបានជ្រាបថា៖ ក្រសួងអប់រំ យុវជន និងកីឡា នឹងរៀបចំប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតមូលដ្ឋានឯកទេសអប់រំកាយ និងកីឡា ១២+២ ចំនួន**៧៥នាក់** និងកម្រិតបរិញ្ញាបត្រសិល្បៈមនុស្សសាស្ត្រ ឯកទេសអប់រំកាយ ១២+៤ ចំនួន**២៥នាក់** ឱ្យចូលរៀននៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា។

ក្នុងការជ្រើសរើសនេះ ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់បែងចែកកន្លែងត្រូវទៅបំពេញការងារតាមខេត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជា មានដូចខាងក្រោម៖

| ល.រ | អង្គភាព | កម្រិតមូលដ្ឋាន | | សរុប |
|---|---|---|---|---|
| | | ១២+២ | ១២+៤ | |
| ១ | ខេត្តស្ទឹងត្រែង | ១ នាក់ | ២ នាក់ | ៣ នាក់ |
| ២ | ខេត្តព្រះវិហារ | ១ នាក់ | ១ នាក់ | ២ នាក់ |
| ៣ | ខេត្តកោះកុង | ២ នាក់ | ១ នាក់ | ៣ នាក់ |
| ៤ | ខេត្តរតនគិរី | ២ នាក់ | | ២ នាក់ |
| ៥ | ខេត្តមណ្ឌលគិរី | ១ នាក់ | | ១ នាក់ |
| ៦ | ខេត្តកណ្តាល | | ៣ នាក់ | ៣ នាក់ |
| ៧ | ខេត្តកំពង់ឆ្នាំង | ២ នាក់ | ២ នាក់ | ៤ នាក់ |
| ៨ | ខេត្តកំពង់ស្ពឺ | ២ នាក់ | | ២ នាក់ |
| ៩ | ខេត្តបាត់ដំបង | ៧ នាក់ | ២ នាក់ | ៩ នាក់ |
| ១០ | ខេត្តពោធិ៍សាត់ | ៤ នាក់ | ៣ នាក់ | ៧ នាក់ |
| ១១ | ខេត្តបន្ទាយមានជ័យ | ៥ នាក់ | ២ នាក់ | ៧ នាក់ |



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

| | | | | |
|---|---|---|---|---|
| ១២ | ខេត្តសៀមរាប | ១០ នាក់ | ៣ នាក់ | ១៣ នាក់ |
| ១៣ | ខេត្តឧត្តរមានជ័យ | ៣ នាក់ | | ៣ នាក់ |
| ១៤ | ខេត្តប៉ៃលិន | ២ នាក់ | | ២ នាក់ |
| ១៥ | ខេត្តកំពង់ចាម | ៤ នាក់ | ១ នាក់ | ៥ នាក់ |
| ១៦ | ខេត្តត្បូងឃ្មុំ | ៥ នាក់ | ២ នាក់ | ៧ នាក់ |
| ១៧ | ខេត្តកំពង់ធំ | ៣ នាក់ | ២ នាក់ | ៥ នាក់ |
| ១៨ | ខេត្តក្រចេះ | ៦ នាក់ | | ៦ នាក់ |
| ១៩ | ខេត្តព្រៃវែង | ១០ នាក់ | | ១០ នាក់ |
| ២០ | ខេត្តស្វាយរៀង | ៣ នាក់ | ១ នាក់ | ៤ នាក់ |
| ២១ | ខេត្តព្រះសីហនុ | ២ នាក់ | | ២ នាក់ |
| | **សរុបរួម** | ៧៥នាក់ | ២៥នាក់ | ១០០នាក់ |

**I- លក្ខខណ្ឌនៃការជ្រើសរើស**

១- បេក្ខជនទាំងពីរភេទត្រូវមានសញ្ជាតិជាខ្មែរ។

២- បេក្ខជនទាំងពីរភេទត្រូវមានអាយុចាប់ពី**១៧ឆ្នាំ** ដល់ **២៥ឆ្នាំ** គិតត្រឹមថ្ងៃប្រឡង។

**បញ្ជាក់៖** - បេក្ខជនអាយុ១៧ឆ្នាំ ថ្ងៃខែឆ្នាំកំណើតត្រឹម **២២ ខែតុលា ឆ្នាំ២០០៦** មានសិទ្ធប្រឡង

- បេក្ខជនអាយុ២៥ឆ្នាំ ថ្ងៃខែឆ្នាំកំណើតត្រឹម **២២ ខែតុលា ឆ្នាំ១៩៩៨** មានសិទ្ធប្រឡង។

៣- បេក្ខជនទាំងពីរភេទត្រូវនៅលីវរហូតដល់បញ្ចប់ការបណ្តុះបណ្តាល។

៤-បេក្ខជនទាំងពីរភេទត្រូវមានសុខភាពល្អ កាយសម្បទាមាំមួន និងគ្រប់លក្ខណៈ ត្រូវពិនិត្យកាយសម្បទាមុនពេលប្រឡងនៅនាយកដ្ឋានសុខភាពសិក្សានៃក្រសួងអប់រំយុវជននិងកីឡា(អគាររដ្ឋបាលថ្មីចៅពញាហុក)។

- បេក្ខជន ៖ នារី ត្រូវមានកម្ពស់ចាប់ពី ១,៥៥ ម៉ែត្រ ឡើងទៅ
- បេក្ខជន ៖ បុរស ត្រូវមានកម្ពស់ចាប់ពី ១,៦៥ ម៉ែត្រ ឡើងទៅ

៥- បេក្ខជនទាំងពីរភេទត្រូវមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រសមមូលឡើងទៅ។

**កំណត់សម្គាល់៖**

- មិនអនុញ្ញាតឱ្យបេក្ខជនមកពីក្រៅខេត្តរបស់ខ្លួនដាក់ពាក្យសុំចុះឈ្មោះប្រឡងឡើយ (ផ្អែកលើសញ្ញាបត្រ ឬវិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាទុតិយភូមិជាគោល)
-បេក្ខជនទាំងអស់អាចដាក់ពាក្យសុំចុះឈ្មោះប្រឡងជ្រើសរើសបានតែមួយប្រព័ន្ធគឺ១២+២ឬ១២+៤។ ករណីបេក្ខជនដាក់ពាក្យសុំចុះឈ្មោះប្រឡងទាំងពីរប្រព័ន្ធក្នុងពេលតែមួយ ត្រូវដកបេក្ខភាពចេញពីការប្រឡងទាំងពីរប្រព័ន្ធដោយស្វ័យប្រវត្តិ
- ក្នុងករណីបេក្ខជនដែលបានប្រឡងជាប់ជាស្ថាពរហើយមិនមកដាក់ពាក្យចូលរៀន ហួសរយៈពេល ១៥ថ្ងៃនៃថ្ងៃឈប់ទទួលពាក្យចូលរៀន វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា នឹងស្នើសុំទៅក្រសួងអប់រំ យុវជន និងកីឡា លុបឈ្មោះចេញពីបញ្ជីប្រឡងជាប់ជាស្ថាពរ
- ក្រសួងអប់រំ យុវជន និងកីឡា រក្សាសិទ្ធិក្នុងការកែប្រែការរៀបចំប្រឡងជ្រើសរើសគ្រូបង្រៀននេះ តាមការចាំបាច់។

## II- លក្ខខណ្ឌនៃការដាក់ពាក្យសុំប្រឡង

១- បេក្ខជនត្រូវជ្រើសរើសយកអនុវិទ្យាល័យ ឬវិទ្យាល័យតែមួយដែលមានឈ្មោះតម្រូវការគ្រូបង្រៀនឯកទេសអប់រំកាយ និងកីឡារបស់ខេត្តនោះ ហើយត្រូវសរសេរលើសំណុំលិខិតអំណះអំណាងរបស់បេក្ខជន។

២-សំណុំលិខិតអំណះអំណាងរបស់បេក្ខជនត្រូវមានចំណាររយល់ព្រមរបស់នាយក/នាយិកាឬគណៈគ្រប់គ្រងអនុវិទ្យាល័យ ឬវិទ្យាល័យរបស់ខេត្តនោះ។

៣- បេក្ខជនធ្វើកិច្ចសន្យាបំពេញការងារនៅអនុវិទ្យាល័យ ឬវិទ្យាល័យរបស់ខេត្តនោះទុកពេលបញ្ចប់ការបណ្តុះបណ្តាលជាស្ថាពរ។

៤-សំណុំលិខិតអំណះអំណាង និងកិច្ចសន្យារបស់បេក្ខជនទុកជូនថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡាពិនិត្យសម្រេចលើលទ្ធផលប្រឡងជ្រើសរើសសម្រាប់ការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា។

**បញ្ជាក់៖** ក្រោយពីប្រឡងបញ្ចប់ការបណ្តុះបណ្តាលជាប់ជាស្ថាពរ គរុសិស្សត្រូវទទួលក្របខណ្ឌជាគ្រូបង្រៀនកម្រិតមូលដ្ឋានឯកទេសអប់រំកាយ និងកីឡា។ ហើយក្នុងករណីគរុសិស្សមិនទៅបំពេញការងារតាមកន្លែងដែលបានជ្រើសរើសយក និងបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡានោះទេ នឹងត្រូវលុបឈ្មោះចេញពីបញ្ជីក្របខណ្ឌ។

## III- សំណុំលិខិតដែលត្រូវបំពេញរួមមាន៖

១- សញ្ញាបត្រ ឬវិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាទុតិយភូមិ ច្បាប់ថតចម្លង ០១សន្លឹក មានបញ្ជាក់និត្យានុកូលកម្មពីសាលារាជធានី-ខេត្តដោយភ្ជាប់មកជាមួយនូវសញ្ញាបត្រ ច្បាប់ដើមមកជាមួយផង។

| | |
|---|---|
| ២- ពាក្យសុំចុះឈ្មោះប្រឡង | ចំនួន ០១ច្បាប់ |
| ៣- ជីវប្រវត្តិសង្ខេប (មានបិទរូបថតថ្មី ) | ចំនួន ០១ច្បាប់ |
| ៤- លិខិតបញ្ជាក់កិរិយាមាយាទ | ចំនួន ០១ ច្បាប់ |
| ៥- រូបថត ៤x៦ (ថតថ្មីចំពីមុខគ្មានពាក់មួក ឬវ៉ែនតា) | ចំនួន ០៣ សន្លឹក |
| ៦- បង្កាន់ដៃបង់ប្រាក់សុំសិទ្ធិប្រឡង | ចំនួន ០១ ច្បាប់ |
| ៧- សលាកប័ត្រឯកត្តជន (មានបិទរូបថតថ្មី) | ចំនួន ០២ ច្បាប់ |
| ៨- លិខិតធានារបស់ឪពុក ម្តាយ ឬអាណាព្យាបាល | ចំនួន ០១ ច្បាប់ |
| ៩- កិច្ចសន្យា | ចំនួន ០១ ច្បាប់ |
| ១០- លិខិតបញ្ជាក់សុខភាព និងកាយសម្បទា | ចំនួន ០១ ច្បាប់ |
| ១១- លិខិតអំណះអំណាងរបស់បេក្ខជន | ចំនួន ០១ ច្បាប់ |

## IV- កន្លែងទទួលពាក្យប្រឡង

- នៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា ដែលមានទីតាំងនៅផ្លូវលេខ៥៩៨ ភូមិលូ សង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ រៀងរាល់ម៉ោងធ្វើការ
- កាលបរិច្ឆេទនៃការទទួលពាក្យចុះឈ្មោះប្រឡង ចាប់ពីថ្ងៃប្រកាសផ្សាយជូនដំណឹងនេះ រហូតដល់ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២៣ វេលាម៉ោង ១៧:០០ នាទីរសៀល
- ចំពោះព័ត៌មានផ្សេងៗសូមទំនាក់ទំនងផ្ទាល់នៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡារៀងរាល់ម៉ោងធ្វើការ។

**កំណត់សម្គាល់៖** បេក្ខជនអាចទាញយកសំណុំលិខិតសុំចុះឈ្មោះប្រឡងពីគេហទំព័ររបស់ក្រសួងអប់រំ យុវជន និងកីឡា www.moeys.gov.kh និងនៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា។

## V- កាលបរិច្ឆេទប្រឡង មណ្ឌលប្រឡង និងវិញ្ញាសាប្រឡង៖

១- កាលបរិច្ឆេទប្រឡង៖ ថ្ងៃទី ២២ ខែតុលា ឆ្នាំ២០២៣ ប្រឡងវិញ្ញាសាសរសេរ និងថ្ងៃបន្តបន្ទាប់ ប្រឡងវិញ្ញាសាអនុវត្តន៍កីឡា

២- មណ្ឌលប្រឡង៖

- **មណ្ឌលប្រឡងវិញ្ញាសាសរសេរ** ៖ នឹងជូនដំណឹងនៅពេលក្រោយ
- **មណ្ឌលប្រឡងវិញ្ញាសាអនុវត្តន៍កីឡា** ៖ នៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា

៣- វិញ្ញាសាប្រឡង៖

**ក- វិញ្ញាសាសរសេរ** ៖ កម្មវិធីថ្នាក់ទី ១២

១- វប្បធម៌ទូទៅ ៖ រយៈពេល ១ ម៉ោង ៣០ នាទី

២- ជីវវិទ្យា ៖ រយៈពេល ១ ម៉ោង ០០ នាទី

៣- ភាសាអង់គ្លេស ៖ រយៈពេល ១ ម៉ោង ០០ នាទី

**ខ- វិញ្ញាសាអនុវត្តន៍កីឡា** ៖

១- នារីរត់៨០ម៉ែត្រ និង បុរសរត់១០០ម៉ែត្រ

២- លោតចម្ងាយ នារី-បុរស

៣- បោលដុំដែក នារីទម្ងន់៣គីឡូក្រាម និង បុរសទម្ងន់៥គីឡូក្រាម

**កំណត់សម្គាល់៖**

-ចាប់ពីប្រកាសលទ្ធផលប្រឡងជាប់ជាស្ថាពរ បេក្ខជនត្រូវមកដាក់ពាក្យសុំចូលរៀននៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា រហូតដល់**ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣** វេលាម៉ោង១៧:០០នាទីរសៀល ជាការកំណត់ចុងក្រោយ

- កាលបរិច្ឆេទចូលរៀន**ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៣** នៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា។

ថ្ងៃព្រហស្បតិ៍ ៤រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០២៣

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**ចម្លងជូន ៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងមុខងារសាធារណៈ

"ដើម្បីជូនជ្រាបជាព័ត៌មាន"

-គ្រប់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន

-គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា

"ដើម្បីជូនជ្រាប និងជួយផ្សព្វផ្សាយ"

-កាលប្បវត្តិ ឯកសារ វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា